# ការដោះលែងលោកស្រី សៀង ចាន់ហេង៖ សង្គមស៊ីវិលយល់ថា ជាការសម្របសម្រួលបញ្ហាផ្ទៃក្នុងរវាងអ្នកមានអំណាច។

*អង្គការសង្គមស៊ីវិល ដែលតាមដានបញ្ហាដីធ្លី កត់សម្គាល់ថា ការសម្រេចដោះលែងលោកស្រី សៀង ចាន់ហេង នាយកក្រុមហ៊ុន ហេង អភិវឌ្ឍន៍ អាចជាការសម្របសម្រួលបញ្ហាផ្ទៃក្នុងនៃគម្រោងអភិវឌ្ឍរវាងអ្នកមានអំណាច។ ការកត់សម្គាល់នេះ ធ្វើឡើងបន្ទាប់ពី ប្រមុខរដ្ឋាភិបាល លោក ហ៊ុន សែន បានសម្រេចលុបចោលការចាប់ខ្លួនលោកស្រី សៀង ចាន់ហេង ជាបណ្ដោះអាសន្ន ដោយរង់ចាំការផ្តល់យោបល់បន្តពីលោកឧបនាយករដ្ឋមន្ត្រី ជា សុផារ៉ា។*



*លោកស្រី ហ៊ុន ប៊ុនធឿន មានតួនាទីជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាទីប្រឹក្សាគណៈសង្ឃនាយក គណៈមហានិកាយ (ឆ្វេង) និង លោកស្រី សៀង ចាន់ហេង នាយកក្រុមហ៊ុន ហេង អភិវឌ្ឍ (ស្តាំ) © សហការី*

លោក វណ្ណ សូផាត អ្នកសម្របសម្រួលផ្នែកដីធ្លីរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃព្រហស្បតិ៍នេះថា ករណីលោកស្រី សៀង ចាន់ហេង ដែលគេស្គាល់ថា ជានាយកក្រុមហ៊ុន ហេង អភិវឌ្ឍ ដែលទទួលកាន់កាប់គម្រោងអភិវឌ្ឍមួយចំនួនរបស់រដ្ឋាភិបាលនោះ អាចមានការសម្របសម្រួលបញ្ហាផ្ទៃក្នុងរវាងអ្នកមានអំណាច ទើបលោកស្រី អាចគេផុតពីការអនុវត្តច្បាប់ពេលនេះ។

ការអះអាងនេះធ្វើឡើងដ្បិត ករណីលោកស្រី សៀង ចាន់ហេង ដែលបានប៉ះទង្គិចទំនាស់ដីធ្លីជាមួយឈ្មោះ ហ៊ុន ប៊ុនធឿន នោះ គឺជាប្អូនស្រីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោកស្រី ហ៊ុន ប៊ុនធឿន មានតួនាទីជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាទីប្រឹក្សាគណៈសង្ឃនាយក គណៈមហានិកាយ។

អ្នកសម្របសម្រួលផ្នែកដីធ្លីនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សូផាត យល់ថា ករណីដោះលែងលោកស្រី សៀង ចាន់ហេង ជារឿងអយុត្តធម៌មួយទៀត ដែលអ្នកមានឥទ្ធិពលអាចសម្របសម្រួលគ្នា

ខណៈដែលបញ្ហាទំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋជាហូរហែកន្លងមក មិនមានដំណោះស្រាយជាប្រសិទ្ធិភាពគួរឲ្យកត់សម្គាល់នោះឡើយ។

លិខិតមួយរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី០៥មករា បានបង្គាប់ឲ្យអាជ្ញាធរចាប់ខ្លួនលោកស្រី សៀង ចាន់ហេង និងបក្ខពួក ដើម្បីចោទប្រកាន់ និងផ្ដន្ទាទោសតាមផ្លូវច្បាប់ដោយមិនលើកលែង ក្នុងករណីក្លែងបន្លំឯកសារ ដើម្បីកាន់កាប់ដីធ្លីគម្រោងសាងសង់ព្រលានយន្តហោះថ្មីរបស់រដ្ឋាភិបាល នៅក្នុងខេត្តកណ្ដាល ដែលមានឈ្មោះកាន់កាប់ដោយលោកស្រី ហ៊ុន ប៊ុនធឿន និងលោកស្រីឧកញ៉ា ហៀវ លន់។

ក៏ប៉ុន្តែស.ជ.ណ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃពុធទី១១មករា សម្រេចលុបចោលភ្លាម ដោយលោកអះអាងថា លោកបានទទួលសំណើពីលោកស្រី សៀង ចាន់ហេង កាលពីថ្ងៃទី០៩មករា។ បើតាមលោក ហ៊ុន សែន ករណីលោកស្រី សៀង ចាន់ហេង ដែលបានក្លែងបន្លំឯកសារកាន់កាប់ដីធ្លីលោស្រី ហ៊ុន ប៊ុនធឿន នឹងត្រូវសម្រេចនាពេលក្រោយ លោកឧកនាយករដ្ឋមន្ត្រី ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ផ្ដល់យោបល់រួចរាល់៕